Greater Dandenong

# សេវាកាកសំណល់សម្រាប់ពលរដ្ឋក្រុង Greater Dandenong



## នៅពេលដែលអ្នកចូលទៅរស់នៅ

### ការកែច្នៃឡើងវិញ



ធុងវត្ថុកែច្នៃឡើងវិញដែលមានគម្របពណ៌លឿងរបស់អ្នកគឺសម្រាប់ក្រដាសនិងក្រដាសកាតុង ដបនិងក្រឡធ្វើពីកែវ កំប៉ុង និងប្រអប់ជ័រ។ វត្ថុក្នុងធុងនេះត្រូវបានប្រមូលយក នៅរៀងរាល់ពេលពីរសប្តាហ៍។

**គន្លឹះជំនួយ**

- ✓ ដាក់វត្ថុកែច្នៃឡើងវិញរបស់អ្នកឲ្យរាត់រាយពីគ្នា មិនមែនដាក់ទៅក្នុងស្បោងឡើយ
- ✗ គ្មានជ័រទន់
- ✗ គ្មានសំរាមឬវត្ថុកែច្នៃឡើងវិញដែលដាក់ទៅក្នុងស្បោង
- ✗ គ្មានថ្មពិលឬធុងឧស្ម័ន

### គ្រឿងសរីរាង្គអាហារនិងសួនច្បារ




ធុងគម្របពណ៌បៃតងរបស់អ្នកគឺសម្រាប់ស្លឹកឈើ ស្មៅ រុក្ខជាតិតូចៗឥតប្រយោជន៍ មែកឈើតូចៗ ផ្កានិងសំណល់អាហារ។ វត្ថុក្នុងធុងនេះត្រូវបានប្រមូលយក នៅរៀងរាល់ពេលពីរសប្តាហ៍ នៅសប្តាហ៍ខុសគ្នាទៅនឹងធុងវត្ថុកែច្នៃរបស់អ្នក។

**គន្លឹះជំនួយ**

- ✓ ទ្រាប់ធុងរបស់អ្នកជាមួយនឹងកន្សែងក្រដាសឬកាសែត
- ✗ គ្មានស្បោង ទ្រនាប់ ឬស្រទាប់វេចខ្ចប់
- ✗ គ្មានផើងរុក្ខជាតិ ដី កំណាត់ឈើ ឬសម្ភារៈសំណង់
- ✗ គ្មានសំរាមអាចម៍នោមឆ្មា ឬលាមកសត្វ

### សំរាម



ធុងគម្របក្រហមរបស់អ្នកគឺសម្រាប់សំរាមដែលមិនអាចកែច្នៃឡើងវិញបាន។ សំរាមនេះត្រូវបានប្រមូលយកនៅរៀងរាល់សប្តាហ៍។

**គន្លឹះជំនួយ**

- ✓ ធ្វើឲ្យច្បាស់ថា គម្របនឹងបិទជិត
- ✗ កុំធ្វើឲ្យធុងរបស់អ្នកមានសំរាមហូរហៀរ
- ✗ គ្មានថ្មពិលឬធុងឧស្ម័ន
- ✗ គ្មានគ្រឿងអគ្គិសនី ថ្នាំលាប ឬសារធាតុគីមី

### ការដាក់ធុងរបស់អ្នកទៅក្រៅ

ធុងគួរតែត្រូវបានដាក់នៅតាមចិញ្ចើមផ្លូវរបស់អ្នក នៅពេលយប់មុនថ្ងៃប្រមូលយក។ ដើម្បីឆែកមើលថ្ងៃប្រមូល សូមឆែកមើលតាមវ៉ិបសៃរបស់សាលាក្រុង ឬទូរសព្ទទៅកាន់ក្រុមសេវាអតិថិជនតាមលេខ 8571 1000។ ទីកន្លែងធំៗមានផ្ទះល្វែងច្រើនអាចមានការរៀបចំធុងរួមគ្នា ហេតុនេះសូមទាក់ទងប្រធានគ្រប់គ្រងគេហដ្ឋានរបស់អ្នកសម្រាប់ព័ត៌មានបន្ថែម។ ដើម្បីស្វែងដឹងនូវថ្ងៃប្រមូលធុងរបស់អ្នក សូមចូលទៅកាន់វ៉ិបសៃ greaterdandenong.vic.gov.au/find-my-bin-day

# សេវាកាកសំណល់សម្រាប់ពលរដ្ឋក្រុង Greater Dandenong




## ការប្រមូលកាកសំណល់រឹង




ទុកបម្រុងជាមុននូវការប្រមូលយកកាកសំណល់រឹងប្រចាំឆ្នាំដោយឥតគិតថ្លៃរបស់អ្នក សម្រាប់វត្ថុដែលមិនចង់បាន ដូចជាគ្រឿងសង្ហារឹម ពូក សំណល់ដែក គ្រឿងអគ្គិសនីធំៗដូចជាទូទឹកកកឬម៉ាស៊ីនបោកខោអាវ និងគ្រឿងអគ្គិសនីទាំងឡាយ។

ទុកបម្រុងជាមុននៅតាមវ៉ិបសៃ **greaterdandenong.vic.gov.au/hardwaste** ឬទូរសព្ទទៅលេខ 03 9721 1915។

សម្រាប់បញ្ជីពេញលេញនៃវត្ថុដែលអាចទទួលយកបាន សូមសាកសួរឆែកមើល នៅពេលអ្នកធ្វើការទុកបម្រុងជាមុននូវការប្រមូលយករបស់អ្នក។

## នៅល្អពេកដើម្បីបោះចោល? ផ្តល់ជីវិតថ្មីទៅឲ្យវត្ថុរបស់អ្នក។



សាកប្រើ Facebook Marketplace, Gumtree ឬ eBay ដើម្បីលក់ឬធ្វើអំណោយនូវវត្ថុដែលអ្នកមិនត្រូវការតទៅទៀត ដោយមានរួមទាំងឡាំងក្រដាសទំនេរសម្រាប់ប្ដូរទីលំនៅ។

មានអង្គការសប្បុរសធម៌ជាច្រើនដែលទទួលយកវត្ថុដែលនៅតែមានស្ថានភាពល្អ។ អង្គការជាច្រើននឹងទៅយកពីអ្នកដោយឥតគិតថ្លៃ។ សូមទាក់ទងអង្គការសប្បុរសធម៌ក្នុងតំបន់របស់អ្នកដើម្បីបញ្ជាក់នូវអ្វីៗដែលអាចទទួលយកបាន។

## ប្រើឡើងវិញ និង កែច្នៃឡើងវិញ

**ថ្ងៃទម្លាក់ចោល**



ថ្ងៃទម្លាក់ចោលវត្ថុប្រើឡើងវិញនិងកែច្នៃឡើងវិញ គឺជាឱកាសល្អមួយដើម្បីសម្អាតកន្លែងខ្លះនៅជុំវិញផ្ទះ កាត់បន្ថយកន្លែងចាក់សំរាម និងផ្តល់វត្ថុនានានូវជីវិតថ្មី។ សេវាឥតគិតថ្លៃនេះគឺជាការបន្ថែមទៅលើការប្រមូលកាកសំណល់រឹងប្រចាំឆ្នាំដោយឥតគិតថ្លៃរបស់អ្នក។

ចូលទៅកាន់វ៉ិបសៃរបស់យើងសម្រាប់កាលបរិច្ឆេទនៅពេលខាងមុខ។
**greaterdandenong.vic.gov.au/recycle-day**

## Recycle Mate (ក្លើកែច្នៃឡើងវិញ)

ភាន់ច្រឡំអំពីធុងមួយណាសម្រាប់ប្រើ ឬរបៀបបោះចោលវត្ថុមិនចង់បានដោយមានសុវត្ថិភាព?

អញ្ជើញទៅកាន់ Recycle Mate ដើម្បីស្វែងដឹងចម្លើយសម្រាប់វត្ថុជាង 7,000 មុខ ដូចជាថ្មពិល ជ័រស្នោ និងកាកសំណល់អេឡិកត្រូនិក ជាមួយនឹងទីកន្លែងទម្លាក់ចោលនៅក្បែរអ្នក។

ចូលទៅកាន់វ៉ិបសៃ ឬទាញយកកម្មវិធី។

**recyclemate.com.au**

## មុនពេលរើចេញ

ផ្តល់ជាអំណោយ ឬលក់វត្ថុមិនចង់បាន មុនពេលអ្នករើចេញ ឬទុកបម្រុងជាមុននូវការប្រមូលកាកសំណល់រឹងប្រចាំឆ្នាំរបស់អ្នក។

ធ្វើឲ្យច្បាស់ក្នុងការប្រាប់ប្រធានគ្រប់គ្រងរបស់អ្នក នៅពេលដែលអ្នកបានទុកបម្រុងជាមុននូវការប្រមូលកាកសំណល់រឹងរបស់អ្នក។

**រក្សាវាឲ្យស្អាត**

សូមកុំទុកវត្ថុទាំងពួងនៅតាមចិញ្ចើមផ្លូវសម្រាប់ឲ្យនរណាម្នាក់ទៀតយកឲ្យសោះ។ ជានិច្ចជាកាល វាសឹងតែក្លាយទៅជាសំរាម ដែលអាក្រក់មើល អាក្រក់សម្រាប់បរិស្ថាន និងចំណាយច្រើនដើម្បីសម្អាតវាចេញ។

ទីក្រុង Greater Dandenong រឹតតែល្អស្អាតស្ថិតនៅក្នុងកណ្ដាប់ដៃរបស់អ្នក។




តើអ្នកបានឃើញសំរាមដែលបោះចោល ការចោលសំរាម ឬគំនូរគូសវាសតាមទីសាធារណៈ ដែលសាលាក្រុងគួរដឹងឬទេ?

អ្នកអាចទូរសព្ទទៅសាលាក្រុងតាមលេខ 8571 1000 ឬប្រើកម្មវិធី Snap Send Solve ដោយឥតគិតថ្លៃ ដើម្បីរាយការណ៍អំពីបញ្ហាទាំងឡាយ។

ថតរូបបញ្ហានោះ បំពេញព័ត៌មាន និងផ្ញើវាមកឲ្យយើងខ្ញុំ ហើយយើងខ្ញុំនឹងដោះស្រាយវា។

សម្រាប់ព័ត៌មានបន្ថែម និងដើម្បីទាញយកកម្មវិធី សូមចូលទៅវ៉ិបសៃ
**snapsendsolve.com**

---

សម្រាប់ព័ត៌មានបន្ថែមអំពីសេវាកាកសំណល់របស់សាលាក្រុង សូមចូលទៅកាន់វ៉ិបសៃ៖ **greaterdandenong.vic.gov.au/waste**

Greater Dandenong

(03) 8571 1000
council@cgd.vic.gov.au
greaterdandenong.vic.gov.au

NATIONAL RELAY SERVICE
TTY: 133 677
Speak and listen: 1300 555 727
Online: relayservice.gov.au
TIS:13 14 50

Acknowledging Bunurong Country
Follow us: